# ៤-ប្រកាសអន្តរក្រសួងស្តីពីការផ្តល់រង្វាន់លើកទឹកចិត្ត សម្រាប់ឧបត្ថម្ភជូនគណៈកម្មការអន្តរក្រសួងដែលបាន ខិតខំប្រឹងប្រែងប្រមូលចំណូលផល-អនុផលព្រៃឈើ

នាយកដ្ឋានគណនេយ្យហិរញ្ញវត្ថុ
មកដល់ថ្ងៃទី ២៦ ខែ មិនា ឆ្នាំ ២០១៤
លេខ: ១៣៧៥ /
ម៉ោង ..........

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការផ្តល់រង្វាន់លើកទឹកចិត្តសម្រាប់ឧបត្ថម្ភជូនគណៈកម្មការអន្តរក្រសួង ដែលបានខិតខំប្រឹងប្រែងប្រមូលចំណូលផល អនុផលព្រៃឈើ

*********

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៤ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងអនុរដ្ឋលេខាធិការនៃក្រសួង និងរដ្ឋលេខាធិការដ្ឋាន នៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស / រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខនស / រកម/០៩០៨/០១៦ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងបរិស្ថាន

- [illegible]

- ចំណារឯកភាពខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០៥ ខែធ្នូ ឆ្នាំ២០១៣ លើលិខិតលេខ ៨១២៩ សហវ ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៣ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សេចក្តីសម្រេចលេខ 00២ ប្រក.បស្ថ ចុះថ្ងៃទី 0៣ ខែ មករា ឆ្នាំ ២០១៤ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីចុះពិនិត្យវាយតម្លៃផល-អនុផលព្រៃឈើ របស់ក្រសួងបរិស្ថាន

## ស ម្រេ ច

ប្រការ១ :

· ត្រូវបានអនុញ្ញាតឱ្យគណៈកម្មការអន្តរក្រសួងដែលបំពេញភារកិច្ចផ្ទាល់ ចុះធ្វើការវាស់វែង ត្រួតពិនិត្យ បរិមាណ និងវាយតម្លៃឈើ កាត់ទុកប្រាក់ចំណូលដែលបានពីសួយសារផល-អនុផលព្រៃឈើនៅលើដីសម្បទានសេដ្ឋកិច្ច ក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថានចំនួន ៣% ( បីភាគរយ ) សម្រាប់ជាប្រាក់រង្វាន់លើកទឹកចិត្ត និងសម្រាប់ពង្រឹងយន្តការនៃការងារគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនិងនៅសល់ចំនួន៩៧%( កៅសិបប្រាំពីរភាគរយ) ត្រូវបង់ចូលថវិការដ្ឋ ។

ប្រការ២ :

ប្រាក់រង្វាន់ចំនួន ៣% នៃប្រាក់ចំណូលលើការប្រមូលផល-អនុផលព្រៃឈើនេះ ត្រូវបានបែងចែកដូចខាងក្រោម :

-ចំនួន ៥0 % ( ហាសិបភាគរយ) ជាចំណែកលើកទឹកចិត្តមន្ត្រីបំពេញការងារ នៃក្រសួងបរិស្ថាន ក្នុងគណៈកម្មការ

-ចំនួន ៣0 % ( សាមសិបភាគរយ ) ជាចំណែកលើកទឹកចិត្តមន្ត្រីបំពេញការងារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងគណៈកម្មការ

-ចំនួន ២0 % ( ម្ភៃភាគរយ ) ជាចំណែកលើកទឹកចិត្តមន្ត្រីបំពេញការងារ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងគណៈកម្មការ ។

ប្រការ៣ :

មុនពេលបង់ចំណូលពីសួយសារផល-អនុផលព្រៃឈើ ៩៧% ( កៅសិបប្រាំពីរភាគរយ ) ចូលថវិការដ្ឋ ក្រសួងបរិស្ថានត្រូវកាត់ទុកជាមុននូវចំណែកប្រាក់រង្វាន់លើកទឹកចិត្តចំនួន ៣% ( បីភាគរយ ) ។ ការកាត់ទុកជាមុននូវចំណែកប្រាក់រង្វាន់លើកទឹកចិត្តនេះ ត្រូវបានចាត់ទុកថាថវិកាជាតិបានបើកផ្តល់ជាប្រាក់បុរេប្រទានជូនក្រសួងបរិស្ថាន សម្រាប់យកទៅបែងចែកដូចបានកំណត់ក្នុងប្រការ២នៃប្រកាសនេះ ។ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធដែលបានទទួលប្រាក់រង្វាន់នេះ ត្រូវរាយការណ៍ជូនរដ្ឋមន្ត្រីរបស់ខ្លួន នៅរៀងរាល់ពេលដែលមានការបែងចែកប្រាក់រង្វាន់ ។

ប្រការ៤ :

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ៥ :

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធទាំងអស់ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងគណៈកម្មការអន្តរក្រសួង ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសអន្តរក្រសួងនេះ ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៤ តទៅ ។/.

រាជធានីភ្នំពេញ,ថ្ងៃទី១៧ ខែ មករា ឆ្នាំ២០១៤

រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

រដ្ឋមន្ត្រី
ក្រសួងបរិស្ថាន

សាយ សំអាល់

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

លេខ ៤០០ ចល.កសក

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើមនិងបញ្ជូនមក:
- ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
  "ដើម្បីជូនជ្រាប"
- អគ្គាធិការដ្ឋាន
- រដ្ឋបាលព្រៃឈើ
- នាយកដ្ឋាននីតិកម្មកសិកម្ម
- នាយកដ្ឋានផែនការនិងស្ថិតិ
- នាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ
  "ដើម្បីជ្រាបនិងអនុវត្ត"

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មករា ឆ្នាំ២០១៤

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
រដ្ឋលេខាធិការ

ឈរ ចិត្រា